# ឯ.ឧ ស៊ូរ យ៉ុន ចែកអំណោយដល់កងទ័ពនៃកងពលតូចថ្មើរជើងលេខ ៤១ អន្លង់វែង ខេត្ត ឧត្តរមានជ័យ





ក្នុងឱកាសនៃបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរនាឆ្នាំនេះ **ឯកឧត្តម ស៊ូរ យ៉ុន** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រួមដំណើរដោយ ឯ.ឧ ជារដ្ឋលេខាធិការ , ឯ.ឧ អនុរដ្ឋលេខាធិការ និង មន្ត្រីថ្នាក់ដឹកនាំក្រោមឱវាទក្រសួងព្រមទាំងតំណាងក្រុមហ៊ុនមួយចំនួន បានអញ្ជើញជួបសំណេះសំណាលចែកអំណោយជូនដល់ នាយទាហាន នាយទាហានរង ពលទាហានកងពលតូចលេខថ្មើរជើងលេខ ៤១ អន្លង់វែង ខេត្ត ឧត្តរមានជ័យនៅ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៩ ។

ក្នុងឱកាសនោះលោកឧត្តមសេនីយ៍ត្រី **នាង ឃីម** មេបញ្ជាការកងពលតូចលេខថ្មើរជើង លេខ ៤១ មានប្រសាសន៍ថាផ្ដើមចេញពីស្មារតីពិធីសារសម្ព័ន្ធមេត្រីភាពរវាង កងពលតូចលេខថ្មើរជើង លេខ ៤១ និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលបានចុះហត្ថលេខានាថ្ងៃទី១៤ ខែ ឧសភា ឆ្នាំ ២០០៦ កន្លងមក កងពលតូចតែងតែទទួលបានការជួយឧបត្ថម្ភជ្រោមជ្រែងទាំងស្មារតី និង សំភារៈពីក្រសួងជាបន្តបន្ទាប់ដែលរួមមានសំភារៈប្រើប្រាស់គ្រឿងឧបភោគ បរិភោគ ថវិកា និង ការសាងសង់នូវសមិទ្ធផល នានាសំរាប់បំរើដល់ផលប្រយោជន៍និងការរស់នៅរបស់កងទ័ព និងគ្រួសារកងទ័ព ។ សកម្មភាពទាំងនេះគឺជាការបង្កលក្ខណៈងាយស្រួលក្នុងការសំរេចភារៈកិច្ចកសាងពង្រឹងអង្គភាព ក៏ដូចភារកិច្ចការពារជាតិមាតុភូមិ ដែលធ្វើអោយនាយទាហាន ពលទាហាន ចងចាំមិនភ្លេចនូវទឹកចិត្ត និងកាយវិការដ៏វិសេសវិសាលប្រកបដោយមនោសញ្ចេតនាចំពោះកងទ័ព ។

មានប្រសាសក្នុងឱកាសនោះ **ឯកឧត្តម ស៊ូរ យ៉ុន**បានសំដែងនូវការកោតសរសើរនិងវាយតំលៃខ្ពស់ចំពោះទឹកចិត្តអង់អាចក្លាហានរបស់ នាយទាហាន ពលទាហានទាំងអស់ ដែលបានកំពុងឈរជើងថែរក្សារ និងការពារទឹកដីហើយពេលនេះសំខាន់ជាងពេលណាៗទាំងអស់ដែលយើងទាំងអស់គ្នា ទាំងកងកំលាំងប្រដាប់អាវុធ រដ្ឋអំណាយគ្រប់មូលដ្ឋានគ្រប់ជាន់ថ្នាក់ និង ប្រជាជនកម្ពុជាទាំងមូលរួមសាមគ្គីគ្នា សហការគ្នា ការពារទប់ទល់ជាមួយនិងរាល់ល្បិចកលឈ្លានពានមកលើដែនដីនៃប្រទេសកម្ពុជា និងរក្សាអោយបាននូវបូរណភាពទឹកដីដ៏ថ្លៃថ្លា ដែលដូនតាយើងបានរក្សាទុករហូតមកដល់ពេលនេះ ។

**ឯកឧត្តម ស៊ូរ យ៉ុន** រដ្ឋមន្ត្រីបានគូសបញ្ជាក់ដែរថាវីរៈភាពរបស់ នាយទាហាន ពលទាហានទាំងអស់ដែលកំពង់ឈរជើងថែរក្សានិងការពារទឹកដីនាពេលនេះគឺជាពលីកម្មដ៏ឧត្តុងឧត្តមពុំអាចកាត់ថ្លៃបាន ។ **ឯកឧត្តម ស៊ូរ យ៉ុន** ក្នុងនាមមន្ត្រីរាជការទាំងអស់ក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ចងចាំទុកជានិច្ចក្នុងក្រអៅបេះដូងដែលមិនអាចបំភ្លេចបានបានឡើយ ។ ទន្ទឹមនឹងនេះដែលសូមកោតសរសើរ និង ដឹងគុណ ចំពោះគ្រួសាររបស់យុទ្ធជនពលីជីវិត និង យុទ្ធជនពិការដែលបានលះបង់ កូន ប្តី ឬឱពុកជាទីស្រឡាញ់របស់ខ្លួន ដើម្បីបុព្វហេតុការពារជាតិមាតុភូមិ អោយរួចផុតពីការចូលទន្ទ្រានកាន់កាប់របស់សត្រូវ ។ ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តម ស៊ូរ យ៉ុន** សន្យាថា និងបន្តខិតខំស្វែងរកនូវអំណោយផ្សេងៗពីសប្បុរសជននានា ដើម្បីយកមកបន្តជួយដល់

នាយទាហាន ពលទាហាន និង ក្រុមគ្រួសារកងទ័ពក្នុងន័យចែករំលែកការលំបាកជាមួយ និង បងប្អូនទាំងអស់គ្នា ។

ក្នុងឱកាសនោះ **ឯកឧត្តម សូរ ឃុន**បានផ្តល់អំណោយជូនដល់បញ្ជាការដ្ឋានកងពលតូចលេខថ្មើរជើង លេខ ៤១ នូវម៉ាស៊ីនថតចំលង ០១ គ្រឿង , កុំព្យុទ័រ ០២ គ្រឿង , ម៉ាស៊ីនព្រីនធ័រ ០២ គ្រឿង , មី ១០០ កេះ, ជីកអណ្តូងស្នប់ចំនួន ០២ , ស្រាបៀរចំនួន៥០កេះ, ទឹកក្រូច ចំនួន ១០ កេះ ,ទឹកសុទ្ធ ចំនួន ១០ កេះ  ជាមួយនេះឧបត្ថម្ភដល់គ្រួសារកងទ័ពចំនួន ១០០ គ្រួសារក្នុងមួយគ្រួសារទទួលបាន កន្ទេល ០១ ,មី ៥០កញ្ចប់ , ភួយ ០១ , មុង ០១ , សារុង ០១ , ក្រម៉ា ០១ សាប៊ូ ០១ កញ្ចប់ , មីចេង ០១ កញ្ចប់ ប្រេងកូឡា ០២ ប្រអប់ ថ្នាំពេទ្យ ០៣ មុខ ០៦ បន្ទះ , ឆៃប៉ូវ ០១ គីឡូក្រាម និង ថវិកា ៥០,០០០ រៀល ។

នៅទីបញ្ចប់ក៏មានការរៀបចំពិធីហូបបាយសាមគ្គី រាំវ៉ៃក និងលេងល្បែងប្រជាប្រិយ៍ដើម្បីអបអរសារទរទទួលទេវតាឆ្នាំថ្មីរហូតដល់ម៉ោង  ១៥ ល្ងាច ។









